UNITED NATIONS
CAMBODIA

# ការគាំទ្ររបស់អង្គការសហប្រជាជាតិដល់វិស័យអប់រំកម្ពុជា នៅក្នុងបរិបទកូវីដ ១៩
# ឯកសារព័ត៌មានទី ១០
# ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២១

ការអប់រំមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការអភិវឌ្ឍផ្ទាល់ខ្លួន និងសក្តានុពលពេញមួយជីវិត របស់កុមារ។ ការអប់រំ គឺជាគន្លឹះដើម្បីគេចចេញពីភាពក្រីក្រ កាត់បន្ថយវិសមភាព និងជំរុញការអភិវឌ្ឍដោយចីរភាព។ ការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ បានបង្កការរំខានដល់ការអប់រំ និងការចូលរៀន នៅទូទាំងសកលលោក។ នៅកម្ពុជា សាលារៀនបានបិទទ្វារជាង ២០០ ថ្ងៃមកហើយ ចាប់គិតតាំងពីខែមីនា ឆ្នាំ ២០២០ មក ដែលបង្កការរំខានដល់ការរៀនសូត្ររបស់សិស្សប្រមាណ ៣,២ លាននាក់។ ការខាតបង់ការអប់រំនាំឱ្យការអភិវឌ្ឍមនុស្សត្រូវថយចុះយ៉ាងគំហុក។ ការប៉ាន់ប្រមាណពីសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) របស់កម្ពុជាសម្រាប់ឆ្នាំ ២០២០ បង្ហាញឱ្យឃើញពីការថយចុះ ៣,៩៣% ចាប់ពីឆ្នាំ ២០១៩ មក ស្មើនឹងការលុបចោលនូវឧឡនភាពទាំងឡាយដែលសម្រេចបាននៅក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយនេះ។[១] មុនពេលមានការរាតត្បាតជាសកលនេះ ប្រទេសកម្ពុជាបានងាកចេញពីគន្លង ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទី ៤ ស្តីពីការរៀនសូត្រប្រកបដោយគុណភាពរួចទៅហើយ ហើយការរាតត្បាតជាសកលនេះរឹតតែធ្វើឱ្យអន្តរាយដល់វឌ្ឍនភាព ដែលសម្រេចបានកន្លងមកទៅទៀត។ គេមិនទាន់ដឹងនៅឡើយទេ ថាតើពេលណាទើបសាលារៀនអាចបើកដំណើរការឡើងវិញ។ នៅពេលដែលពេលវេលាកាន់តែអូសបន្លាយពេលយូរ ហានិភ័យដែលកុមារមិនអាចត្រឡប់ទៅសាលារៀនវិញកើនឡើងកាន់តែខ្ពស់ ជាពិសេសកុមារមកពីក្រុមងាយរងគ្រោះ។ ការរាតត្បាតជាសកលបានបង្កើនវិសមភាពដែលមានរួចទៅហើយ និងអាចធ្វើឱ្យគម្លាតឌីជីថលកាន់តែរីកធំបន្ថែមទៀត។ ការបិទទ្វារសាលារៀនបង្កផលប៉ះពាល់ផ្សេងទៀត ក្រៅតែពីលើការរៀនសូត្រ ដូចជាបង្កផលប៉ះពាល់ដល់លទ្ធភាពរបស់មាតាបិតា និងអ្នកផ្តល់ការថែទាំជាច្រើន ជាពិសេសស្ត្រី ក្នុងការធ្វើការងារ ធ្វើឱ្យកុមារជាច្រើននាក់មិនសូវអាចទទួលបានអាហារដែលសំបូរសារជាតុចិញ្ចឹម និងបង្កើនហានិភ័យនៃការប្រព្រឹត្តិអំពើហិង្សាលើកុមារ។ ភស្តុតាងក្នុងសកលលោកទាំងមូល បន្តបង្ហាញឱ្យឃើញថា សាលារៀនមិនមែនជាកន្លែងដែលនាំឱ្យមានការចម្លងជំងឺខ្លាំងក្លាជាងគេនោះឡើយ ដូច្នេះសាលារៀនអាចបើកដំណើរការឡើងវិញប្រកបដោយសុវត្ថិភាព[២]។

---

១ UNDP, "ការព្យាករណ៍ពីផលប៉ះពាល់នៃជំងឺកូវីដ ១៩ មកលើសន្ទស្សន៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០២០ របស់កម្ពុជា និងប្រទេសក្បែរខាង", https://www.kh.undp.org/content/cambodia/en/home/library/projected-impacts-of-covid-19-on-the-2020-human-development-inde.html.

២ យូនីសេហ្វ និងយូណេស្កូ "ការបើកដំណើរការសាលារៀនឡើងវិញពុំអាចរងចាំបានឡើយ", https://www.unicef.org/press-releases/statement-reopening-schools-cannot-wait

ចាប់តាំងពីពេលដែលការរាតត្បាតជាសកលនេះចាប់ផ្ដើមកើតមានឡើង អង្គការសហប្រជាជាតិបានធ្វើការងារជាដៃគូ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំយុវជន និងកីឡា ដើម្បីជួយឱ្យប្រទេសនេះអាចសម្របខ្លួនឆ្លើយតប និងស្តារឡើងវិញពីផលប៉ះពាល់ដោយសារជំងឺកូវីដ ១៩ បង្កលើការអប់រំ។ កិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិមានគោលបំណងផ្តល់ការគាំទ្រគ្រប់ជ្រុងជ្រោយដល់កុមារ ដើម្បីជួយឱ្យអ្នកសិក្សាគ្រប់រូប នៅតែអាចបន្តទទួលបានការអប់រំប្រកបដោយគុណភាពនៅទូទាំងប្រទេស និងដើម្បីធានាយ៉ាងណាមិនឱ្យមានកុមារណាម្នាក់ត្រូវបានគេទុកចោល។

ការវាយតម្លៃរួមគ្នាលើតម្រូវការនៃវិស័យអប់រំ[៣] ដែលធ្វើឡើងរួមគ្នាដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រុមការងារវិស័យអប់រំ ដែលមានអង្គការសហប្រជាជាតិជាប្រធាន បានរកឃើញថា កុមារមានឱកាសមិនដូចគ្នាឡើយ ក្នុងការបន្តការរៀនសូត្ររបស់ពួកគេ ដែលនាំឱ្យមានការបាត់បង់ការរៀនសូត្រយ៉ាងច្រើន នៅគ្រប់កម្រិត។ ខណៈពេលដែលមានកុមារប្រមាណ ៧០% អាចបន្តការអប់រំរបស់ខ្លួន មានកុមារប្រមាណ ៣០% ប៉ុណ្ណោះ ដែលមានលទ្ធភាពប្រើប្រាស់ខ្លឹមសារមេរៀនតាមប្រព័ន្ធអនឡាញ និង ៣២% ពឹងអាស្រ័យតែលើឯកសារមេរៀនតែប៉ុណ្ណោះ។ កុមារមកពីគ្រួសារក្រីក្រ ឬរស់នៅជាមួយពិការភាព បន្តជួបប្រទះនឹងបញ្ហាប្រឈមច្រើនជាងគេ។ កាលវិភាគបង្ហាញថាមានគ្រួសារ ៤០% រាយការណ៍ថាមានអាហារញ៉ាំតិចតួចជាងមុន ហើយមានក្មេងប្រុស និងក្មេងស្រី ២០% រាយការណ៍ដោយខ្លួនឯងថាបានប្រឈមនឹងហានិភ័យនៃអំពើហិង្សា ឬការរំលោភបំពានកាន់តែច្រើនជាងមុនក្នុងអំឡុងពេលដែលសាលារៀនបិទទ្វារ។

ដើម្បីជួយឱ្យកុមារបន្តការរៀនសូត្រក្នុងអំឡុងពេលដែលសាលារៀនបិទទ្វារ អង្គការសហប្រជាជាតិ និងដៃគូបានខិតខំផលិតខ្លឹមសារមេរៀនពីចម្ងាយ សម្រាប់កុមារនៅកម្រិតថ្នាក់ទាំងអស់។ ខ្លឹមសារទាំងនេះរួមមានខ្លឹមសារដែលបង្ហោះតាមថ្នាលបច្ចេកវិទ្យាអនឡាញ ទូរទស្សន៍ និងវិទ្យុ។ ឯកសាររៀនពីចម្ងាយក្នុងទម្រង់ជាក្រដាសក៏ត្រូវបានចែកជាប្រចាំដល់សិស្សទូទាំងប្រទេសផងដែរ ជាពិសេស វាបានផ្តល់ជាប្រយោជន៍ដល់កុមារជួបការលំបាក ដែលពុំមានអ៊ីនធឺណិតប្រើប្រាស់ ឬពុំអាចចូលប្រើប្រាស់ថ្នាលបច្ចេកវិទ្យាសម្រាប់ចែករំលែកព័ត៌មានដទៃទៀត។ ក្នុងករណីពាក់ព័ន្ធ ឯកសារមេរៀនទាំងនេះត្រូវបានបកប្រែជាភាសាជនជាតិភាគតិចចំនួន ៤ ការអក្សរស្ទាប និងជាភាសាសញ្ញាកម្ពុជា។ កញ្ចប់ឯកសារសិក្សាតាមផ្ទះសម្រាប់កុមារទាំងអស់ដែលរៀននៅសាលារដ្ឋ ថ្នាក់ទី ១ និងថ្នាក់ទី ២ (ប្រមាណ ៧៥០ 000 នាក់) ក៏ត្រូវបានផ្តល់ជូនផងដែរ ដោយសារតែកុមារនៅក្នុងក្រុមអាយុនេះងាយនឹងបាត់បង់ការរៀនសូត្រ។ កញ្ចប់ឯកសារបន្ថែមរៀបចំជា ៤ ភាសាដែលជាភាសាជនជាតិដើមភាគតិច បានដល់ដៃកុមារចំនួន ៥ 000 នាក់នៅភូមិភាគឦសាននៃប្រទេសកម្ពុជា។ ព័ត៌មានអំពីការការពារជំងឺកូវីដ ១៩ និងវ៉ាក់សាំងការពារជំងឺកូវីដ ១៩ ក៏ត្រូវបានបញ្ចូលទៅក្នុងកញ្ចប់ឯកសារនេះផងដែរ ដើម្បីជួយគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំង។

ដោយឡែក ក្នុងអនុវិស័យអប់រំក្រៅប្រព័ន្ធវិញ អង្គការសហប្រជាជាតិកំពុងពង្រីកកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាយ៉ាងណាឱ្យ សិស្សមធ្យមសិក្សាបឋមភូមិ និងយុវជនក្រៅសាលាយ៉ាងហោចណាស់ ៣00 000 នាក់ (ស្រី ៥០%) អាចបន្តទទួលបានធនធានសិក្សាដែលមានបច្ចុប្បន្នភាពបំផុត តាមរយៈថ្នាលកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (BEEP)។ ដោយសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា អង្គការសហប្រជាជាតិកំពុងពង្រីកថ្នាល

[៣] ក្រសួងអប់រំយុវជន និងកីឡា និងក្រុមការងារវិស័យអប់រំ, "ការវាយតម្លៃរួមគ្នាលើតម្រូវការក្នុងវិស័យអប់រំ", https://www.unicef.org/cambodia/reports/needs-assessment-helps-understand-impact-covid-19-education-stakeholders

BEEP នេះបន្ថែមទៀត ដើម្បីធានាឱ្យអ្នកសិក្សាជាច្រើននាក់បន្ថែមទៀតអាចបន្តការរៀនសូត្ររបស់ពួកគេ។ ក្រសួងក៏បានបើកមជ្ឈមណ្ឌល BEEP នៅតាមតំបន់ដាច់ស្រយាល រៀបចំខ្លឹមសារមេរៀនក្នុងទម្រង់ឌីជីថល និងផ្តល់នូវឱកាសរៀនសូត្របំពេញបន្ថែមប្រកបដោយភាពទន់ភ្លន់ ជាជម្រើសផ្សេងទៀត ដល់សិស្សដែលកំពុងរៀននៅតាមសាលាមធ្យមសិក្សាបឋមភូមិ។

អង្គការសហប្រជាជាតិក៏បានផ្តល់ការគាំទ្រយ៉ាងច្រើនដល់គ្រូបង្រៀនផងដែរ។ ឧទាហរណ៍ កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំត្រូវបានរៀបចំឡើង ដោយត្រូវបានសម្របតាមគន្លងអាជីពគ្រូបង្រៀន។ អង្គការសហប្រជាជាតិក៏កំពុងផ្តល់ការគាំទ្រដល់ការរៀនសូត្រពីចម្ងាយ និងការរៀនសូត្រតាមប្រព័ន្ធអនឡាញ តាមរយៈការទិញឧបករណ៍ថាប្លែត (Tablets) និងផ្តល់កញ្ចប់អ៊ីនធឺណិតប្រើប្រាស់ដោយមិនគិតថ្លៃ ជូនគ្រូឧទ្ទេសទាំងអស់ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រឹត្យការខេត្ត។ អង្គការសហប្រជាជាតិបានសម្របសម្រួលការរៀបចំ និងការអនុវត្តដល់កម្មវិធីវិក្រឹត្តការ ដោយប្រើប្រាស់វិធីសាស្ត្រចម្រុះ ដើម្បីបង្កើនសមត្ថភាព ICT របស់គ្រូឧទ្ទេស និងវិធីសាស្ត្របង្រៀនបែបនវានុវត្តន៍សម្រាប់ការអប់រំអនឡាញពីចម្ងាយ នៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រឹត្តការខេត្ត។

ដោយទទួលស្គាល់ពីផលប៉ះពាល់ ដែលការអនុវត្តវិធានការរឹតត្បិត ដើម្បីការពារជំងឺកូវីដ ១៩ មានមកលើលទ្ធភាពរបស់គ្រួសារក្រីក្រក្នុងការបំពេញតម្រូវការស្បៀង និងអាហារូបត្ថម្ភ ក្នុងអំឡុងពេលដែលសាលារៀនបិទទ្វារ អង្គការសហប្រជាជាតិបានបង្វែរធនធាន ដែលប្រើប្រាស់សម្រាប់កម្មវិធីអាហារតាមសាលារៀន ទៅជាការបែងចែករបបស្បៀងជូនកុមារមកពីគ្រួសារក្រីក្រ ដែលជាធម្មតាតែងទទួលបានអាហារពីកម្មវិធីផ្តល់អាហារតាមសាលារៀន ដែលអនុវត្តនៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា។ គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ តាមរយៈការសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា អង្គការសហប្រជាជាតិបានផ្តល់ជំនួយ ៤ លើកដល់ប្រជាពលរដ្ឋជាង ៩០ 000 គ្រួសារក្នុងខេត្តចំនួន ១០ ដែលជាការបំពេញបន្ថែមដល់កិច្ចខិតខំប្រឹងប្រែងសង្គ្រោះគ្រួសារដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ ១៩ ដោយបានជួយឱ្យគ្រួសារទាំងនេះ អាចបំពេញតម្រូវការអាហាររបស់ខ្លួន និងលើកទឹកចិត្តឱ្យគ្រួសារក្រីក្រនៅតែបន្តឱ្យកូនបានទៅរៀនទៀត។

ដើម្បីគាំទ្រដល់ការបើកដំណើរការសាលារៀនឡើងវិញប្រកបដោយសុវត្ថិភាព ក្នុងឆ្នាំ ២០២០ អង្គការសហប្រជាជាតិបានផ្តល់សម្ភារៈសម្អាត និងធ្វើអនាម័យដល់សាលារៀនរដ្ឋទាំង ១៣ ៣០០ កន្លែងនៅកម្ពុជា ផ្តល់ជាប្រយោជន៍ដល់សិស្ស ៣,២ លាននាក់។ រួមគ្នាជាមួយនឹងដៃគូផ្តល់ថវិកាគាំទ្រ អង្គការសហប្រជាជាតិបានផ្តល់ថវិកា ៤,២ លានដុល្លារ ជូនសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិទូទាំងប្រទេស មុនពេលចាប់ផ្តើមបវេសនកាលឆ្នាំថ្មីក្នុងខែមករា ឆ្នាំ ២០២១ ដើម្បីជួយឱ្យសាលារៀនអាចរ៉ាប់រងចំណាយបន្ថែមទៀត ពាក់ព័ន្ធនឹងការផ្តល់សេវាអប់រំ ក្នុងបរិបទកូវីដ ១៩។

ការអប់រំផ្សព្វផ្សាយអំពីហានិភ័យ និងការកៀរគរចលនាសហគមន៍ជុំវិញសាលារៀន ក៏បានទទួលការគាំទ្រពីអង្គការសហប្រជាជាតិផងដែរ។ កាលពីខែកញ្ញា ឆ្នាំ ២០២០ អង្គការសហប្រជាជាតិ រួមជាមួយនឹងក្រសួងអប់រំយុវជន និងកីឡា បានប្រកាសដាក់ឱ្យអនុវត្តយុទ្ធនាការត្រឡប់ទៅសាលារៀនវិញទូទាំងប្រទេស ដោយបានគូសបញ្ជាក់ពីសារៈសំខាន់នៃការអនុវត្តអនាម័យល្អ និងវិធានការការពារជំងឺកូវីដ ១៩។ គម្រោងហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដែល ផ្តោតលើសម្ភារៈទឹកស្អាត និងអនាម័យ ត្រូវបានពង្រីកវិសាលភាព ដើម្បីធានាឱ្យមានបរិក្ខាគ្រប់គ្រាន់ សម្រាប់ការវិលត្រឡប់ទៅកាន់សាលា

រៀនវិញប្រកបដោយប្រសិទ្ធភាព។ ដំណាក់កាលទី ២ នៃយុទ្ធនាការត្រឡប់ទៅសាលារៀនវិញ ដែលអនុវត្តទូទាំងប្រទេស បានចាប់ផ្តើមធ្វើឡើង ក្នុងខែមករា ឆ្នាំ ២០២១ ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពទាំងអស់នៃសុខមាលភាពរបស់កុមារដូចជា៖ ការអប់រំ សុខភាពអាហារូបត្ថម្ភ និងការការពារជាដើម។ ការរៀបចំសៀវភៅណែនាំស្តីពី "ដំណើរការសាលារៀនប្រកបដោយសុវត្ថិភាព" (១១៣ ០០៦ ច្បាប់) និងការចែកសៀវភៅទាំងនេះដល់សាលារៀនជាង ១៦ ០០០ កន្លែងក្នុងប្រទេសកម្ពុជា បានជួយឱ្យគ្រូបង្រៀន និងនាយកសាលាអាចត្រៀមខ្លួន សម្រាប់ឆ្នាំសិក្សាថ្មី។

ដើម្បីបំពេញបន្ថែមដល់យុទ្ធនាការនេះ អង្គការសហប្រជាជាតិបានវិនិយោគលើគំនិតផ្តួចផ្តើមរយៈពេល ១២ ខែ មួយដែលមានឈ្មោះថា គំនិតផ្តួចផ្តើមអប់រំផ្សព្វផ្សាយដើម្បីការអប់រំ (C4E) ក្នុងគោលដៅបង្កើតតម្រូវការនៃការអប់រំនៅតាមសហគមន៍ និងគណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន លើការផ្តល់សេវាអប់រំដែលធានាបាននូវសុវត្ថិភាព ពីជំងឺកូវីដ ១៩។ គំនិតផ្តួចផ្តើមនេះមានគោលបំណងផ្សព្វផ្សាយសារដល់សហគមន៍ងាយរងគ្រោះនៅក្នុងខេត្តគោលដៅចំនួន ៦ (រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ កំពង់ឆ្នាំង កោះកុង)។ ចាប់តាំងពីការបិទទ្វារសាលារៀនកាលពីថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២១ មក ទាំងយុទ្ធនាការត្រឡប់ទៅកាន់សាលារៀនវិញ ទាំងគំនិតផ្តួចផ្តើមអប់រំផ្សព្វផ្សាយដើម្បីការអប់រំ ត្រូវបានកែសម្រួល ដើម្បីបញ្ចូលសារលើកទឹកចិត្តឱ្យកុមារបន្តរៀនសូត្រតាមរយៈកម្មវិធីសិក្សាពីចម្ងាយ ក្រោមការជួយជ្រោមជ្រែងពីឪពុកម្តាយ និងលោកគ្រូអ្នកគ្រូ។

អង្គការសហប្រជាជាតិ សូមវាយតម្លៃខ្ពស់ដល់គំនិតផ្តួចផ្តើមរបស់កម្ពុជា ដែលចាត់ទុកការផ្តល់វ៉ាក់សាំងដល់គ្រូបង្រៀនថាជាអាទិភាព។ កម្ពុជា គឺជាប្រទេសមួយ ក្នុងចំណោមប្រទេស ១៧ ដែលផ្តល់អាទិភាពដល់ការចាក់វ៉ាក់សាំងគ្រូបង្រៀន ហើយរហូតមកដល់បច្ចុប្បន្ននេះ មានគ្រូរដ្ឋ និងឯកជនប្រមាណ ៨៥% បានទទួលវ៉ាក់សាំងគ្រប់ដូស។ អង្គការសហប្រជាជាតិក៏ទទួលស្គាល់ពីការប្រកាស ដែលធ្វើឡើងកាលពីពេលថ្មីៗនេះ ដោយរាជរដ្ឋាភិបាល ដែលបញ្ជាក់ថាប្រទេសនេះកំពុងពិចារណាចាក់វ៉ាក់សាំងដល់កុមារអាយុពី ១២ ដល់ ១៧ ឆ្នាំ។ ប៉ុន្តែ បច្ចុប្បន្ននេះ គេនៅកំពុងប្រមែប្រមូលភស្តុតាង និងគោលនយោបាយណែនាំស្តីពីការចាក់វ៉ាក់សាំងកូវីដ ១៩ ដល់កុមារ នៅឡើយ។ ស្របតាមការណែនាំជាសកលបច្ចុប្បន្នរបស់អង្គការសុខភាពពិភពលោក និងដោយសារការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ ១៩ នៅមានកម្រិត អង្គការសហប្រជាជាតិ ផ្តល់ជាអនុសាសន៍ឱ្យមានការបន្តផ្តល់អាទិភាពវ៉ាក់សាំងដល់មនុស្សពេញវ័យ និងអ្នកដែលប្រឈមមុខខ្ពស់ទៅនឹងការឆ្លងជំងឺ ក៏ដូចជាក្រុមដែលងាយរងគ្រោះជាងគេមុនសិន។ កុមារដែលមានជំងឺប្រចាំកាយ ហើយដែលងាយនឹងឆ្លងជំងឺកូវីដ ១៩ ធ្ងន់ធ្ងរគួរទទួលបានវ៉ាក់សាំង ប៉ុន្តែទាល់តែក្រោយពេលដែលមនុស្សពេញវ័យភាគច្រើន ដែលមានជំងឺប្រចាំកាយ បានទទួលវ៉ាក់សាំង ២ ដូសសិន។ គួរមានការរៀបចំផែនការសម្រាប់ពេលអនាគត ហើយប្រទេសទាំងឡាយដែលពិចារណាផ្តល់វ៉ាក់សាំងដល់មនុស្សវ័យក្មេងក៏ចាំបាច់ត្រូវពិចារណាពីសុវត្ថិភាព និងប្រសិទ្ធភាពនៃវ៉ាក់សាំងកូវីដ ១៩ សម្រាប់កុមារផងដែរ ដែលត្រូវថ្លឹងថ្លែងពីហានិភ័យ និងអត្ថប្រយោជន៍ដែលអាចមាន។

ការចូលរួមយ៉ាងសកម្មរបស់ក្រសួងអប់រំយុវជន និងកីឡា នៅក្នុងសម្ព័ន្ធអប់រំសកល ដែលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបចំពោះជំងឺកូវីដ ១៩ ក៏ត្រូវបានទទួលស្គាល់ផងដែរ រួមគ្នានឹងការប្តេជ្ញាចិត្តរបស់ក្រសួងអប់រំយុវជន និងកីឡា ក្នុងការវិភាជថវិកាចំណាយសម្រាប់ការអប់រំឱ្យដល់ ២០% នៃថវិកាចំណាយសរុបរបស់រដ្ឋាភិបាល ពោលគឺកើនឡើងពីតួលេខ ១៨,៣៨% ចាប់ពីឆ្នាំ ២០២២ តទៅ។ ការធានាឱ្យមានការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ដល់វិស័យអប់រំ មានសារៈ

សំខាន់សម្រាប់ការស្តារឡើងវិញ ជួយប៉ះប៉ូវការបាត់បង់ការអប់រំ ដែលកើតមានក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលនេះ។

ការអប់រំគឺជាសិទ្ធិជាមូលដ្ឋាន និងជាកត្តាជំរុញឱ្យមានការសម្រេចវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍ដោយប្រកបចីរភាពទាំង ១៧។ អង្គការសហប្រជាជាតិបន្តលើកទឹកចិត្ត និងគាំទ្រឱ្យរាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពដល់ការបើកដំណើរការ សាលារៀនឡើងវិញឱ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន និងបន្តបើកសាលាឱ្យយូរបំផុត ដើម្បីបញ្ចៀសការបន្តធ្លាក់ចុះនៃការអភិវឌ្ឍមនុស្ស។ ប្រកាសដែលចេញកាលពីពេលថ្មីៗ ដើម្បីអនុញ្ញាតឱ្យមានការរៀនជាក្រុមតូច បានទទួលការស្វាគមន៍ជាជំហានទី ១។ ការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ គឺជាឱកាស ដើម្បីកែលម្អប្រព័ន្ធសម្រាប់ការអប់រំប្រកបដោយគុណភាព ដើម្បីធានាយ៉ាងណាឱ្យកុមារគ្រប់រូបអាចសម្រេចសក្តានុពលពេញលេញរបស់ពួកគេ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលគួរបន្តកិច្ចខិតខំប្រឹងប្រែងកសាងប្រព័ន្ធអប់រំដែលមានលក្ខណៈបរិយាបន្ន និងធន់ទៅនឹងវិបត្តិនៃការរំខាននាពេលអនាគត។ នេះរាប់បញ្ចូលការបង្កើនការវិនិយោគលើចំណេះដឹងឌីជីថល ប្រកបដោយគុណភាព ការភ្ជាប់ទំនាក់ទំនង និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រដល់ការបន្តការសិក្សា ក៏ដូចជាបង្កើនជំនាញរបស់គ្រូ ក្នុងការបញ្ចូលបច្ចេកវិទ្យា ICT ទៅក្នុងការរៀននិងបង្រៀន។ គួរមានការបង្កើនការយកចិត្តទុកដាក់លើកុមារដែលប្រឈម និងត្រូវបានគេទុកចោល ជួយប៉ះប៉ូវការបាត់បង់ការសិក្សារបស់ពួកគេ និងជួយគាំទ្រដល់ការអភិវឌ្ឍសុខមាលភាពរបស់ពួកគេ។ អង្គការសហប្រជាជាតិនៅតែបន្តប្តេជ្ញាចិត្ត ក្នុងការសហការជាមួយនឹងរាជរដ្ឋាភិបាល ក៏ដូចជាដៃគូដទៃទៀត ដើម្បីលើកកម្ពស់ការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ ក៏ដូចជាជួយស្តារឡើងវិញពីការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ដើម្បីបង្កើនភាពធន់បន្ថែមទៀត។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង និងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។